**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារជូនពរ

**ផ្ញើជូន**

**នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ**

**ក្នុងឱកាសពិធីចូលឆ្នាំថ្មី ឆ្នាំសកល២០២០**

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !**

ក្នុងឱកាសដ៏វិសេសវិសាល ប្រកបដោយសេចក្តីសោមនស្សរីករាយនៃទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២០ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹកនិងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត ចំពោះមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ សូមទទួលបាននូវសេចក្តីសុខសប្បាយ សម្រេចបានជោគជ័យនូវភារកិច្ចថ្មីៗ និងទទួលបានកិត្តិយសកេរ្តិ៍ឈ្មោះជូនជាតិមាតុភូមិយើង។

នាឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះ ចំពោះជោគជ័យដ៏ត្រចះត្រចង់ ដែលកងយោធពលខេមរភូមិន្ទយើងសម្រេចបាននូវសមិទ្ធផលដ៏ធំធេងក្នុងឆ្នាំកន្លងមក កើតចេញពីការលះបង់ និងការខិតខំពុះពារជម្នះគ្រប់ឧបសគ្គនិងការលំបាក ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ ការពារសន្តិសុខជាតិ ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន។ ទន្ទឹមនេះកងយោធពលខេមរភូមិន្ទយើង បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវភារកិច្ចអន្តរជាតិលើវិស័យមនុស្សធម៌ បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាព ក្រោមឆត្ររបស់អង្គការសហប្រជាជាតិ នៅបណ្តាតំបន់មួយចំនួនដូចជា " **អាហ្វ្រិក អឺរ៉ុប និងមជ្ឈិមបូព៌ា**" ដើម្បីបុព្វហេតុសន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាក្តីមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូល។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះនិងវាយតម្លៃខ្ពស់ចំពោះវីរភាពស្នាដៃដ៏ធំធេង ដែលសម្រេចបាននាពេលកន្លងមក។

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ជាទីស្នេហា !**

ជាថ្មីម្តងទៀតក្នុងទិវាចូលឆ្នាំថ្មីឆ្នាំសកលនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូនចំពោះនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធ-

ពលខេមរភូមិន្ទ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ជូនជាតិមាតុភូមិនៃយើង។

សូមផ្ញើជូននូវការសួរសុខទុក្ខដល់យោធិន **ជំងឺ របួស ពិការ** ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឱ្យបានឆាប់ជាសះស្បើយពីជំងឺ មានសុខភាពល្អបរិបូរណ៍ កម្លាំងរឹងមាំ និងប្រកបដោយសេចក្តីសុខ។ សូមជូនពរដល់អតីតយុទ្ធជន ព្រមទាំងក្រុមគ្រួសារដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានជីវភាពរស់នៅធូរធានិងប្រកបដោយសុភមង្គលរុងរឿង។

សូមផ្ញើជូន មេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន កងឯកភាព នាយទាហាន នាយទាហានរង និងពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ទាំងសិក្ខាកាមដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗនៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់អង្គការសហប្រជាជាតិ ព្រមទាំងក្រុមគ្រួសារ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃព្រហ ៧រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៩
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**